## មេរៀនទី១៧ ភ្លឺបមុខវិជ្ជា

## I- វត្ថុបំណង

ក្រោយពីបញ្ចប់មេរៀននេះ គរុសិស្សនឹងៈ

- ប្រាប់បានពីគោលការណ៍រៀបចំក្លឹបតាមមុខវិជ្ជា
- កំណត់បានពីរចនាសម្ព័ន្ធក្លឹប និងសហការជួយគ្នាទៅវិញទៅមកក្នុងការសិក្សា
- មានទម្លាប់ស្រាវជ្រាវ និងស្វ័យសិក្សាជាប្រចាំ ។

## II- សេចក្តីផ្តើម

មេរៀននេះជួយដល់សាលាមធ្យមសិក្សាបឋមភូមិ ដើម្បីផ្តល់ឱកាសដល់គរុសិស្សបានរៀន និងយល់ដឹងឱ្យកាន់តែទូលំទូលាយ បន្ថែមលើសៀវភៅសិក្សាគោល ។ គរុសិស្ស នឹងបង្កើនការរៀនសូត្របានច្រើនរបៀបដូចជា យល់ដឹង និងបង្កើននូវសមត្ថភាពក្នុងការរៀនឱ្យកាន់តែចាប់អារម្មណ៍ថែមទៀត និងមានភាពសមស្របក្នុងកម្មវិធីសាលាកុមារមេត្រី។

## III- ខ្លឹមសារ

### ១- គោលការណ៍រៀបចំក្លឹបមុខវិជ្ជា

#### ក- ការស្ម័គ្រចិត្ត

ការចូលរួមរបស់សិស្សនៅក្នុងក្លឹប មិនមែនសម្រាប់សិស្សទាំងអស់នោះទេ ហើយលោកគ្រូ អ្នកគ្រូមិនត្រូវបង្ខិតបង្ខំសិស្សឱ្យចូលរួមនៅក្នុងក្លឹបទេ ។ សិស្សប្រហែលមានចំណាប់អារម្មណ៍ខុសៗគ្នា ហើយយើងគួរតែណែនាំពួកគេអំពីការបង្កើតក្លឹបនេះ ឱ្យបានសមស្របទៅនឹងបញ្ញត្តិនៃកម្មវិធីសាលាកុមារមេត្រី ។ សិស្សត្រូវបានអនុញ្ញាតឱ្យជ្រើសរើសដោយខ្លួនឯងនូវប្រភេទមុខវិជ្ជាដែលពួកគេចង់សិក្សាឱ្យបានស៊ីជម្រៅ និងសម្រេចចិត្តថា តើខ្លួនមានពេលវេលា និងចំណាប់អារម្មណ៍យ៉ាងណាក្នុងការចូលរួមក្លឹបនេះ ។

ដូចគ្នានេះដែរ គ្រូមិនត្រូវបង្ខិតបង្ខំឱ្យសិស្សបង្កើតក្លឹបនេះទេ ។ ប៉ុន្តែ គ្រូត្រូវពន្យល់អំពីសារៈសំខាន់នៃការចូលរួមក្នុងក្លឹបមុខវិជ្ជា ។ ព្រមជាមួយគ្នានេះដែរ គ្រូស្ម័គ្រចិត្តក៏អាចចំណាយពេលវេលាផ្ទាល់ខ្លួនក្នុងការកសាងផែនការជាមួយនឹងសិស្ស ការចូលរួមប្រជុំ ពិសេសក្រៅម៉ោងសិក្សា និងការដឹកនាំសកម្មភាពរបស់សិស្ស ។ គណៈគ្រប់គ្រងត្រូវពិចារណា លើតម្រូវការមួយចំនួនក្នុងការលើកទឹកចិត្តគ្រូស្ម័គ្រចិត្តដឹកនាំក្លឹប ។

#### ខ- ទំហំក្លឹប

ដើម្បីបង្កឱ្យមានលក្ខណៈងាយស្រួលបំផុតក្នុងការបង្កើតក្លឹប គួរជ្រើសរើសយកគ្រូ និងសិស្សនៅក្នុងសាលារៀនតែមួយ ឬសាលាដែលនៅជិតៗគ្នា ។ ឧទាហរណ៍ សាលាមួយចំនួននៅក្នុងតំបន់គោលដៅ ក៏អាចចូលរួមនៅក្នុងក្លឹបនេះដែរ ។ ករណីបែបនេះ ប្រហែលជាត្រូវមានគ្រូមួយចំនួនដែលត្រូវចូលរួម ព្រមទាំងសិស្សពី៥នាក់ ទៅ១០នាក់ ឬច្រើនជាងនេះពីសាលានីមួយៗ ។

#### គ- កម្រិតថ្នាក់គោលដៅ

នៅអនុវិទ្យាល័យក្លឹបមុខវិជ្ជាអាចបង្កើតបានគ្រប់កម្រិតថ្នាក់ អាស្រ័យលើលទ្ធភាពរបស់គ្រូ និងសិស្ស ដែលពួកគេចាប់អារម្មណ៍លើមុខវិជ្ជាណាមួយ ។

#### ឃ- ការវាយតម្លៃចំណាប់អារម្មណ៍របស់សិស្ស និងការប្រើប្រាស់វគ្គតម្រង់ទិស

ការសម្រេចចិត្តរបស់សិស្សក្នុងការចូលរួមក្លឹប ត្រូវផ្អែកលើការសម្រេចចិត្តដែលបានផ្តល់ព័ត៌មានជាមុន ។ ក្នុងការវាយតម្លៃចំណាប់អារម្មណ៍សិស្សឱ្យចូលរួមក្នុងក្លឹប ជាដំបូងគ្រូត្រូវផ្តល់នូវព័ត៌មាន ការណែនាំបង្ហាញពីសារៈសំខាន់នៃក្លឹបមុខវិជ្ជា ។ វាអាចត្រូវបានធ្វើឡើងតាមរយៈ ការពន្យល់ដោយមាត់ទទេទៅកាន់សិស្សក្នុងថ្នាក់ ឬការពន្យល់ដោយសរសេរ ដែលត្រូវបានបិទនៅតាមទីសាធារណៈ ឬទាំងពីររបៀបតែម្តង ។ ចំណុចមួយចំនួនដែលត្រូវបានរៀបរាប់ នៅក្នុងការណែនាំ គួររួមបញ្ចូលនូវចំណុចដូចខាងក្រោមៈ

- គោលបំណង៖ ផ្តល់ឱកាសវិជ្ជមាន និងគ្មានការបង្ខិតបង្ខំ ដើម្បីអភិវឌ្ឍជំនាញ និងបំណិន
- សកម្មភាព៖ ធ្វើដំណើរទស្សនកិច្ចសិក្សា ការចុះតាមមូលដ្ឋាន កំណត់ត្រាប្រចាំថ្ងៃ ការពិភាក្សាក្រុម អំពីរឿងប្រលោមលោក ការបោះពុម្ពផ្សាយអត្ថបទកាសែត ការនិពន្ធកំណាព្យ ការសរសេរអត្ថបទល្ខោន ការសម្តែងល្ខោន ការរចនាសម្លៀកបំពាក់ ល្បែងភាសាអង់គ្លេស ពិភាក្សាក្រុម ។ល។
- ការវាយតម្លៃ៖ ពុំមានការវាយតម្លៃ ឬការដាក់ពិន្ទុជាលក្ខណៈផ្លូវការទេ ។ សិស្សត្រូវបានធ្វើសកម្មភាពដែល គេចង់ធ្វើ មិនមែនធ្វើដោយបង្ខិតបង្ខំនោះឡើយ ។
- ការចូលរួម៖ សមាជិកក្លឹប ត្រូវចូលរួមដោយស្ម័គ្រចិត្ត ។
- ការប្រជុំ៖ ត្រូវមានការប្រជុំជាទៀងទាត់ ដើម្បីពិភាក្សាសកម្មភាពដែលបានគ្រោងទុក ។ ការប្រជុំនឹងត្រូវធ្វើ ឡើងបន្ទាប់ពីការបង្រៀន ឬនៅពេលដែលសាលាឈប់សម្រាក ។

បន្ទាប់ពីការណែនាំនេះ ត្រូវសួរសិស្សថា តើពួកគេមានចំណាប់អារម្មណ៍ចូលរួមក្នុងក្លឹបមុខវិជ្ជានេះទេ ដោយចង្អុលបង្ហាញនូវកម្រិតនៃការចាប់អារម្មណ៍របស់ពួកគេ ។ ក្នុងការវាយតម្លៃលើចំណាប់អារម្មណ៍សិស្ស សូមប្រើល្បះនៅក្នុងទម្រង់ចំណាប់អារម្មណ៍ ដែលបង្ហាញនៅក្នុងឧបសម្ព័ន្ធទី១ ។ ទម្រង់នេះ មានសារប្រយោជន៍ ពីព្រោះវានឹងការពារមិនឱ្យសិស្សមានការភ័យខ្លាចនឹងនិយាយថាព្រម ឬមិនព្រម ជាពិសេសចម្លើយអំពីការមិនចាប់អារម្មណ៍អាចសម្តែងពីការមិនគោរពទៅលើគ្រូ ។ ត្រូវទុកពេលឱ្យសិស្ស១០ ទៅ១៥នាទី ដើម្បីពិភាក្សាសម្រេចចិត្តដោយខ្លួនឯង មុនពេលបំពេញទម្រង់ និងជូនទម្រង់នោះមកឱ្យគ្រូវិញ ។

**ង- ការបែងចែកតួនាទី និងភារកិច្ច**

នៅក្នុងការប្រជុំក្លឹបលើកដំបូង គ្រូដែលទទួលខុសត្រូវក្លឹបមុខវិជ្ជា ឱ្យសមាជិកទាំងអស់ ជ្រើសរើសប្រធាននៃផ្នែកសំខាន់ៗមួយចំនួន ដែលនឹងត្រូវដើរតួនាទីនៅក្នុងក្លឹបមុខវិជ្ជា ។ ការជ្រើសរើសប្រធាន ត្រូវធ្វើឡើងដោយការបោះឆ្នោត ឬដោយការស្រែកជាសំឡេងគាំទ្រ ។ តួនាទីទាំងនោះមិនបិតថេរទេ ប៉ុន្តែជារួមមាន(១)ប្រធាន (២)អនុប្រធាន និង(៣)លេខា ។ ប្រសិនបើ មានសិស្សច្រើននៅក្នុងក្លឹប(ឧទាហរណ៍ បើមានសមាជិក១៥នាក់ ឬច្រើន) ចាំបាច់ត្រូវមានប្រធានក្រុមមួយសម្រាប់សមាជិក៣ ទៅ៤នាក់ ។ ការទទួលខុសត្រូវសម្រាប់តួនាទីនីមួយៗ ត្រូវបានបង្ហាញនៅក្នុងឧបសម្ព័ន្ធទី២ ។ ការទទួលខុសត្រូវទាំងនេះត្រូវបង្ហាញដល់សមាជិកក្លឹបទាំងអស់ ត្រូវពន្យល់ដោយគ្រូដែលទទួលខុសត្រូវក្លឹប ។ នៅក្នុងជំហានដំបូងរបស់ក្លឹប គ្រូទទួលខុសត្រូវក្លឹបត្រូវមានទំនាក់ទំនងយ៉ាងជិតស្និទ្ធក្នុងការជួយដល់ប្រធានផ្នែករបស់ក្លឹប ដើម្បីបំពេញតួនាទីរបស់ពួកគេឱ្យបានជោគជ័យ ។ ទោះជាយ៉ាងណាក៏ដោយ គ្រូត្រូវចេះផ្ទេរ ការទទួលខុសត្រូវឱ្យបានច្រើនដល់សិស្ស ពួកគេនឹងមានបទពិសោធកាន់តែច្រើនក្នុងការធ្វើការងារផ្សេងៗនៅក្នុងពេលរៀនសូត្រ ។

**ច- ការធ្វើផែនការ**

ការងារមួយក្នុងចំណោមការងារដំបូងទាំងឡាយដែលក្លឹបគួរធ្វើ គឺត្រូវបង្កើតផែនការក្នុងត្រីមាសនីមួយៗ ។ ទម្រង់ផែនការដែលអាចជួយក្លឹបឱ្យសម្រេចនូវសកម្មភាពសម្រាប់សប្តាហ៍នីមួយៗក្នុងខែ (ឧបសម្ព័ន្ធទី៣) ។ មុនពេលបង្កើតផែនការ គ្រូទទួលខុសត្រូវក្លឹបត្រូវត្រួតពិនិត្យ ឡើងវិញនូវសកម្មភាពមួយចំនួនដែលអាចធ្វើទៅបាន ហើយបង្កើតគម្រោង១ ឬ២ដែលក្លឹបនឹងត្រូវធ្វើនៅក្នុងត្រីមាស ។ ឧទាហរណ៍ ក្លឹបនិពន្ធប្រហែលជាចង់បង្កើតកម្មវិធីបង្ហាញមួយ ដើម្បីសរសេរអំពីប្រាសាទបុរាណក្នុងមូលដ្ឋានរបស់ពួកគេ ។ ទោះជាយ៉ាងនេះក្តី មុនពេលចាប់ផ្តើមបង្កើត កម្មវិធីបង្ហាញនោះ គ្រូប្រហែលជាចង់ជួយសម្របសម្រួលសកម្មភាពទាំងឡាយអំពីប្រភេទនៃការសរសេរខុសៗគ្នា ។ សកម្មភាព នេះ រួមមានទាំងកំណាព្យ ឬរឿងខ្លីៗ ។ គ្រូទទួលខុសត្រូវក្លឹបត្រូវដើរតួនាទី ជាអ្នកសម្របសម្រួលសកម្មភាពទាំងឡាយ រហូតទាល់តែសិស្សស៊ាំនឹងសកម្មភាពទាំងនោះ ហើយដឹកនាំការសម្តែងដោយខ្លួនឯង ។ នៅពេលសំណេររបស់ពួកគេ ត្រូវបានធ្វើរួចរាល់ហើយ ក្លឹបត្រូវរៀបចំការតាំងពិព័រណ៍នៅក្នុងបណ្ណាល័យ ឬក្នុងថ្នាក់រៀន

ព្រមទាំងធ្វើការបង្ហាញដល់ សិស្សដទៃទៀតដែលមិនមែនជាសមាជិកក្លឹប ។ សកម្មភាពទាំងអស់នេះ ត្រូវបានសរសេរឡើងនៅក្នុងផែនការ ។ ឧទាហរណ៍ គំរូនៃក្លឹបនិពន្ធនៅក្នុងតារាងដូចខាងក្រោម៖

**គំរូផែនការសកម្មភាពក្លឹបនិពន្ធ (ត្រីមាសទី ១)**

| សកម្មភាព | វិច្ឆិកា | | | | ធ្នូ | | | | មករា | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ |
| ការប្រជុំលើកទី១ ការបោះឆ្នោត និង សកម្មភាពនិពន្ធ | x | | | | | | | | | | | |
| ២- ការប្រជុំលើកទី២ សកម្មភាពនិពន្ធ | | x | | | | | | | | | | |
| - ការប្រជុំលើកទី៣ សកម្មភាពនិពន្ធ | | | X | | | | | | | | | |
| ៤- ការចុះតាមមូលដ្ឋាន | | | | x | | | | | | | | |
| ៥- សកម្មភាពនិពន្ធ | | | | | x | | | | | | | |
| - ផែនការតាំងពិព័រណ៍ | | | | | | x | | | | | | |
| - បង្កើតការតាំងពិព័រណ៍ | | | | | | | x | | | | | |
| - បង្ហាញការតាំងពិព័រណ៍ | | | | | | | | x | | | | |

**ធនធានសម្រាប់ដំណើរការក្លឹប**

ក្លឹបមានដំណើរការប្រកបដោយរលូនមានប្រសិទ្ធភាព វាត្រូវការនូវធនធានច្រើនដូចជា៖ សម្ភារៈកន្លែងប្រជុំ (ឧទាហរណ៍ បណ្ណាល័យ ថ្នាក់រៀនដែលទំនេរ ឬទីធ្លាមួយ...) សៀវភៅរឿង ប្រលោមលោក ឬទស្សនាវដ្តីបន្ទប់កុំព្យូទ័រ សម្រាប់វាយសំណេរច្នៃប្រឌិត ឬធនធានថវិកា ។ ធនធានសម្រាប់តម្រូវការ សកម្មភាពជាក់លាក់មួយចំនួនរួមមាន៖

- ក្រដាសសម្រាប់កត់ត្រា ឬសរសេររបាយការណ៍ (គ្រប់ក្រុម)
- ក្រដាសផ្ទាំងធំសម្រាប់បង្កើតការតាំងពិព័រណ៍
- ហ្វឹតសម្រាប់រៀបចំការតាំងពិព័រណ៍
- ថវិកាសម្រាប់ការធ្វើដំណើរចុះតាមមូលដ្ឋាន
- ម៉ាស៊ីនថតរូប
- ថវិកាសម្រាប់គោលបំណងពិសេសផ្សេងៗ
- ផ្សេងៗ

**១- ប្រភេទក្លឹប**

- ក្លឹបនិពន្ធ
- ក្លឹបប្រវត្តិសាស្ត្រ
- ក្លឹបសិល្បៈ

- ក្លឹបអង់គ្លេស
- ក្លឹប...។

**២- សកម្មភាពក្លឹបមុខវិជ្ជា**

គ្រប់សកម្មភាពដែលក្លឹបអាចរៀបចំ ដើម្បីកែលម្អកិច្ចការ(លំហាត់) គួរឱ្យមានភាពចាប់អារម្មណ៍ និងមានលក្ខណៈ គិត វិភាគ ច្នៃប្រឌិត សម្រាប់សិស្ស ។ រីឯសកម្មភាពដែលបានផ្តល់ឱ្យនៅខាងក្រោមនេះគឺគ្រាន់តែជាឧទាហរណ៍ប៉ុណ្ណោះ ។ គ្រូ និងសមាជិកក្លឹបអាចបញ្ចេញយោបល់ផ្ទាល់ខ្លួនអំពីអ្វីដែលពួកគេចង់ធ្វើដើម្បីពង្រីកនូវឱកាសរៀនសូត្រតាមរយៈការសិក្សាស្រាវជ្រាវនៅក្នុងក្លឹបរបស់ពួកគេ ។

**ក- ក្លឹបនិពន្ធ**

សកម្មភាពក្លឹបនិពន្ធមាន៖

- សំណេរច្នៃប្រឌិត
- កំណាព្យ
- កំណត់ត្រាប្រចាំថ្ងៃ
- សរសេរសំបុត្រ
- ការបោះពុម្ព
- ការជួបជុំ ដើម្បីស្វែងយល់ពីអំណាន
- ការទំនាក់ទំនងរោងពុម្ពក្នុងមូលដ្ឋានសម្រាប់បោះពុម្ពអត្ថបទរឿងរបស់សិស្ស
- ការប្រជុំត្រួតពិនិត្យដើម្បីវាយតម្លៃសកម្មភាពប្រចាំឆ្នាំ ។

**ខ- ក្លឹបប្រវត្តិសាស្ត្រ**

សកម្មភាពក្លឹបប្រវត្តិសាស្ត្រមាន៖

- ការចុះសិក្សាស្រាវជ្រាវ
- សកម្មភាពស្រាវជ្រាវប្រវត្តិសាស្ត្រដោយផ្ទាល់មាត់
- ការតាំងតុនៅក្នុងថ្នាក់រៀន និងក្នុងបណ្ណាល័យ
- ការអញ្ជើញភ្ញៀវដែលអាចបរិយាយអំពីប្រវត្តិអ្វីមួយ

**គ- ក្លឹបសិល្បៈ**

- សកម្មភាពក្លឹបសិល្បៈមាន៖

ការសម្តែងល្ខោន

+ ការសម្តែងកាយវិការ
+ ការបញ្ចូលសំឡេង ឬការនិយាយនៅលើឆាក

- ការបង្កើតការសម្តែង

  + ការជ្រើសរើសអត្ថបទ
  + ការជ្រើសរើសតួអង្គ
  + ដំណើរការឆាក
  + ការរចនាគ្រឿងតុបតែងខ្លួន
  + ការរចនាសម្លៀកបំពាក់
  + ការរចនាឆាក និងគ្រឿងតុបតែងឆាក
  + ការសម្តែង៖ ការសម្តែងនៅក្នុងសិល្បៈសម្តែង

- បណ្ណាល័យ និងផ្ទាំងផ្សព្វផ្សាយព័ត៌មានថ្នាក់រៀន

វិធីដ៏ល្អមួយសម្រាប់ក្លឹបសម្តែងល្ខោន ក្នុងការឱ្យសិស្សដទៃទៀតបានដឹងព័ត៌មានជាប្រចាំគឺត្រូវបង្កើតក្តារខៀនព័ត៌មាននៅក្នុងបណ្ណាល័យ ឬក្នុងថ្នាក់រៀន ។

ក្លឹបរបស់យើង៖ សិស្សអាចបិទរូបថតផ្ទាល់ខ្លួនរបស់ពួកគេដែលស្ថិតក្នុងសម្លៀកបំពាក់ដែលបានរចនា និងការសម្តែងតួនៅក្នុងក្លឹប

ការផ្សព្វផ្សាយការសម្តែង៖ សិស្សអាចបង្កើតក្រដាសផ្សព្វផ្សាយការសម្តែងរបស់ពួកគេនៅពេលខាងមុខ ពេលវេលា និងទីកន្លែង ។ ពួកគេក៏ប្រហែលជាចង់ចូលរួមជាមួយនឹងសមាជិកអ្នកសម្តែងផងដែរ

ការជ្រើសរើស៖ សិស្សអាចសរសេរក្រដាសផ្សព្វផ្សាយតូចៗ ហើយសុំឱ្យសិស្សដទៃជួយដើរបិទដើម្បីសុំជំនួយក្នុងការរៀបចំការសម្តែងល្ខោនដូចជា ការរៀបចំឆាក ឬការច្នៃសម្លៀកបំពាក់ល្ខោន ។

- ការអញ្ជើញពិធីករ
- ការភ្ជាប់ទំនាក់ទំនងក្លឹបជាមួយនឹងការរៀនសូត្ររបស់សិស្សដទៃ

**ឃ- ក្លឹបអង់គ្លេស**

សកម្មភាពក្លឹបនេះមាន៖

- ល្បែងរំលឹកមេរៀនចាស់
- ការស្តាប់ ដើម្បីធ្វើការត្រិះរិះពិចារណា
- ការសរសេរ និងប្រកបពាក្យ
- ការបញ្ចេញសំឡេង
- សំណេរកថាខ័ណ្ឌខ្លីៗ អត្ថបទ...
- ការនិយាយ
- ការច្នៃប្រឌិត
- ការតែងកំណាព្យ
- កំណត់ត្រាប្រចាំថ្ងៃ
- ការសរសេរសំបុត្រ
- ការបោះពុម្ព
- ការចុះស្រាវជ្រាវតាមមូលដ្ឋាន

## IV- សន្និដ្ឋាន

ការបង្កើតក្លឹបមុខវិជ្ជាមានសារៈសំខាន់ណាស់ សម្រាប់ជួយដល់សិស្សដែលជាសមាជិកក្លឹប ដើម្បីចែករំលែកបទពិសោធជាមួយសិស្សដទៃទៀត ។ សកម្មភាព និងគោលការណ៍ជាមូលដ្ឋានរបស់ក្លឹប ដែលបានរៀបរាប់ខាងលើវាបានផ្តល់ឱកាសយ៉ាងពេញលេញដើម្បីពង្រឹង និងពង្រីកចំណេះដឹងសមាជិកក្លឹបឱ្យកាន់តែស៊ីជម្រៅលើមុខវិជ្ជាដែលខ្លួនបានចូលរួម ។ ម្យ៉ាងវិញទៀត សមាជិកក្លឹបមានភាពក្លាហាន និងការប្តេជ្ញាចិត្តក្នុងការដឹកនាំធ្វើការសម្របសម្រួលសកម្មភាពការងារផ្សេងៗទាំងក្នុងថ្នាក់ និងក្រៅថ្នាក់ផងដែរ ។

## សំណួរពិភាក្សា

១- តើគេត្រូវការគោលការណ៍ជាមូលដ្ឋានអ្វីខ្លះដើម្បីរៀបចំក្លឹបមុខវិជ្ជាមួយបាន?

២- តើសកម្មភាពក្នុងក្លឹបមុខវិជ្ជានីមួយៗដូចគ្នា ឬខុសគ្នា? ចូររៀបរាប់សកម្មភាពក្នុងក្លឹបនីមួយៗឱ្យបានច្បាស់លាស់ ។

៣- ចូរបង្ហាញពីសារៈសំខាន់នៃការបង្កើតក្លឹបមុខវិជ្ជា ។

**ឧបសម្ព័ន្ធទី១**

**សេចក្ដីណែនាំ**

ការចូលរួមក្លឹបមុខវិជ្ជា គឺជាឱកាសមួយក្នុងការគិតតាមរយៈសកម្មភាពផ្សេងៗប្រកបដោយភាពច្នៃប្រឌិត ។ នេះគឺជាចំណុចមួយចំនួនដែលអ្នកគួរដឹង មុនពេលអ្នកសម្រេចចិត្តថា តើត្រូវចូលរួមក្លឹប ឬមិនចូលរួម ។

- គោលបំណង៖ ផ្ដល់ឱកាសល្អ និងគ្មានការគំរាមកំហែង ដើម្បីអភិវឌ្ឍចំណេះដឹង និងបំណិនលើមុខវិជ្ជាដែលខ្លួនពេញចិត្តឱ្យកាន់តែស៊ីជម្រៅ ។

- សកម្មភាព៖ ធ្វើដំណើរទស្សនកិច្ចសិក្សា ការចុះតាមមូលដ្ឋាន កំណត់ត្រាប្រចាំថ្ងៃ ការពិភាក្សាក្រុមអំពីរឿងប្រលោមលោក ការបោះពុម្ពផ្សាយអត្ថបទកាសែត ការនិពន្ធកំណាព្យ ការសរសេរអត្ថបទល្ខោន ការសម្ដែងល្ខោន ការរចនាសំលៀកបំពាក់ ល្បែងភាសាអង់គ្លេស ពិភាក្សាក្រុម ។ល។

- ការវាយតម្លៃ៖ ពុំមានការវាយតម្លៃ ឬការដាក់ពិន្ទុជាលក្ខណៈផ្លូវការទេ ។ សិស្សត្រូវបានណែនាំឱ្យធ្វើសកម្មភាពពីព្រោះពួកគេចង់ធ្វើ មិនមែនពីព្រោះពួកគេត្រូវបានបង្ខំទេ ។

- ការចូលរួម៖ សមាជិកក្លឹប ត្រូវស្ម័គ្រចិត្ត ។

- ការប្រជុំ៖ នឹងមានការប្រជុំជាទៀងទាត់ ដើម្បីពិភាក្សាសកម្មភាពដែលបានគ្រោងទុក។ ការប្រជុំនឹងត្រូវធ្វើឡើងបន្ទាប់ពីការបង្រៀន ឬនៅពេលដែលសាលាឈប់សម្រាក ។

**សំណួរ**

ចូរគូសសញ្ញា(✓)នៅក្នុងប្រអប់ណាមួយ ក្នុងចំណោមប្រអប់ទាំងអស់ខាងក្រោម ដើម្បីបញ្ជាក់នូវចំណាប់អារម្មណ៍ របស់អ្នកក្នុងការចូលរួមក្លឹប ៖

□ខ្ញុំមិនចាប់អារម្មណ៍នឹងការចូលរួមក្លឹបនេះសោះ ។

□ខ្ញុំចាប់អារម្មណ៍នឹងការចូលរួមក្លឹប ប៉ុន្តែខ្ញុំមិនច្បាស់ថាខ្ញុំមានពេលវេលាគ្រប់គ្រាន់សម្រាប់វា ឬយ៉ាងណាទេ ។

□ខ្ញុំចាប់អារម្មណ៍នឹងការចូលរួមក្លឹបណាស់ ហើយខ្ញុំច្បាស់ថា ខ្ញុំនឹងមានពេលវេលាគ្រប់គ្រាន់សម្រាប់វា ។

**ឧបសម្ព័ន្ធទី២៖ *ភារកិច្ចរបស់សិស្សដឹកនាំក្លឹបដែលត្រូវបានជ្រើសរើស***

**១- ប្រធាន**

- រៀបចំការប្រជុំក្លឹប
- សម្របសម្រួលរបៀបវារៈសម្រាប់ការប្រជុំនីមួយៗ
- សម្របសម្រួលការប្រជុំ
- ធានាថា កន្លែងប្រជុំត្រូវបានធ្វើឡើង ដោយការសម្របសម្រួលជាមួយនឹងនាយកសាលា
- ទំនាក់ទំនងជាមួយនឹងក្លឹប និងគណៈកម្មការសាលា
- ត្រួតពិនិត្យការអនុវត្តតាមផែនការប្រចាំត្រីមាស
- រាយការណ៍បញ្ហាដល់គ្រូដែលទទួលខុសត្រូវក្លឹប ប្រសិនបើមាន ។

**២- អនុប្រធាន**

- បំពេញតួនាទីជាប្រធាន នៅពេលប្រធានអវត្តមាន
- ជួយសម្របសម្រួលការប្រជុំ
- សរសេរកំណត់ហេតុ ។

**៣- បេឡា**

- ទទួលខុសត្រូវចំពោះថវិកាដែលបានផ្តល់អោយដោយគ្រូទទួលខុសត្រូវក្លឹបសម្រាប់សកម្មភាពផ្សេងៗ រួមមាន ការទិញ សម្ភារៈសម្រាប់តាំងពិព័ណ៌ ការចុះតាមមូលដ្ឋាន ...
- រក្សាទុកកំណត់ហេតុនៃថវិកាទាំងអស់ដែលបានទទួលពីគ្រូទទួលខុសត្រូវក្លឹប
- ទិញ ឬចំណាយតាមការណែនាំរបស់គ្រូទទួលខុសត្រូវក្លឹប ។

**៤- ប្រធានក្រុម**

- គ្រប់គ្រងក្រុម
- ធ្វើរបាយការណ៍តំណាងក្រុមជូនទៅប្រធានក្លឹប ឬគ្រូទទួលខុសត្រូវក្លឹប
- ផ្សព្វផ្សាយព័ត៌មានដែលទទួលបានពីប្រធាន ឬគ្រូទទួលខុសត្រូវក្លឹបទៅឱ្យសមាជិកក្រុម ។

**គ្រូទទួលខុសត្រូវក្លឹប**

- ណែនាំរួមដល់ក្លឹបក្នុងការធ្វើផែនការ រៀបចំការប្រជុំ ជ្រើសរើសប្រធានផ្នែករបស់ក្លឹបដែលចុងក្រោយ ប្រធានផ្នែក នឹងអាចធ្វើការងារដោយខ្លួនឯង
- ជួយផ្នែកបច្ចេកទេសសម្រាប់បញ្ហាដែលទាក់ទងនឹងការសរសេរ(សំណង់ឈ្មោះ វាក្យស័ព្ទ វេយ្យាករណ៍។ល។)
- ធ្វើជាតំណាងក្លឹបប្រចាំគណៈកម្មការទ្រទ្រង់សាលាក្នុងពេលដំណើរការថវិកា
- សម្របសម្រួលសកម្មភាពតាមការធ្វើផែនការ និងការបង្កើតការចុះមូលដ្ឋាន
- សម្របសម្រួលការទំនាក់ទំនងរវាងក្លឹប និងរដ្ឋបាលសាលា សម្រាប់គោលបំណងផ្សេងៗ ដូចជាការប្រើប្រាស់បណ្ណាល័យសម្រាប់ការប្រជុំ...
- ត្រួតពិនិត្យការប្រើប្រាស់ធនធានថវិកាដែលក្លឹបបានធ្វើសកម្មភាព ។

## ឧបសម្ព័ន្ធទី ៣៖ ផែនការក្លឹប

ត្រីមាសទី១៖

| ល.រ | សកម្មភាព | វិច្ឆិកា | | | | ធ្នូ | | | | មករា | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ |
| ១ | | | | | | | | | | | | | |
| ២ | | | | | | | | | | | | | |
| ៣ | | | | | | | | | | | | | |
| ៤ | | | | | | | | | | | | | |
| ៥ | | | | | | | | | | | | | |
| ៦ | | | | | | | | | | | | | |
| ៧ | | | | | | | | | | | | | |
| ៨ | | | | | | | | | | | | | |
| ៩ | | | | | | | | | | | | | |
| ១០ | | | | | | | | | | | | | |

ត្រីមាសទី២៖

| ល.រ | សកម្មភាព | កុម្ភៈ | | | | មិនា | | | | មេសា | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ |
| ១ | | | | | | | | | | | | | |
| ២ | | | | | | | | | | | | | |
| ៣ | | | | | | | | | | | | | |
| ៤ | | | | | | | | | | | | | |
| ៥ | | | | | | | | | | | | | |
| ៦ | | | | | | | | | | | | | |
| ៧ | | | | | | | | | | | | | |
| ៨ | | | | | | | | | | | | | |
| ៩ | | | | | | | | | | | | | |
| ១០ | | | | | | | | | | | | | |